**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

លេខ..៤៣០១..សបត/ប្រសបត

# ប្រកាស

## ស្តីពី

## លក្ខខណ្ឌក្នុងការផ្សព្វផ្សាយពាណិជ្ជកម្មផលិតផលចំណីអាហារ

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផលទំនិញ និងសេវា
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញប្រកាសអន្តរក្រសួងលេខ ៨៦៨ ឧរថប្រក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ២០១០ ស្តីពីការអនុវត្ត និងសម្របសម្រួលស្ថាប័នកិច្ចនៃប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារចាប់ពីកសិដ្ឋានផលិតរហូតដល់តុបរិភោគ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសុខាភិបាល។



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

# សម្រេច

**ប្រការ១ .-**

ប្រកាសនេះមានគោលបំណងការពារសុខភាពអ្នកបរិភោគ និងកំណត់លក្ខខណ្ឌក្នុងការផ្សព្វផ្សាយពាណិជ្ជកម្មផលិតផលចំណីអាហារ ដើម្បីទប់ស្កាត់ការផ្សព្វផ្សាយបំផ្លើសខុសពីការពិត និងការកាត់បន្ថយការពុលចំណីអាហារដែលគ្មានអនាម័យ និងសុវត្ថិភាព។

**ប្រការ២ .-**

ប្រកាសនេះមានគោលដៅគ្រប់គ្រងការផ្សព្វផ្សាយពាណិជ្ជកម្មផលិតផលចំណីអាហារតាមគ្រប់រូបភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣ .-**

ប្រកាសនេះមានវិសាលភាពអនុវត្តការផ្សព្វផ្សាយពាណិជ្ជកម្មផលិតផលចំណីអាហារនៅទូទាំងប្រទេសព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤ .-**

វាក្យសព្ទបច្ចេកទេសដែលប្រើនៅក្នុងប្រកាសនេះរួមមាន៖

- **ការផ្សព្វផ្សាយពាណិជ្ជកម្ម** សំដៅដល់គ្រប់ទង្វើរបស់ផលិតករ ឬអ្នកចែកចាយ ទោះជាតាមមធ្យោបាយណាក៏ដោយ ដែលមានគោលបំណងផ្សព្វផ្សាយលក់ ចែកចាយ ប្រើប្រាស់ ឬដាក់តាំងលក់ផលិតផលចំណីអាហារ។
- **ផលិតចំណីអាហារ** សំដៅដល់ផលិតផលទាំងឡាយណាដែលបានកែច្នៃចទាំងស្រុង ឬកែច្នៃបឋម ឬមិនទាន់បានកែច្នៃក្នុងគោលបំណងបរិភោគដោយមនុស្ស លើកលែងតែផលិតផលឱសថ គ្រឿងញៀន និងថ្នាំជក់។

**ប្រការ៥ .-**

ម្ចាស់គ្រឹះស្ថាននាំចូល នាំចូល អ្នកផលិត អ្នកចែកចាយផលិតផលចំណីអាហារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវដាក់ពាក្យស្នើសុំការផ្សព្វផ្សាយពាណិជ្ជកម្មផលិតផលចំណីអាហារនៅក្រសួងសុខាភិបាល(នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង)។

**ប្រការ៦ .-**

ការសុំផ្សព្វផ្សាយពាណិជ្ជកម្មចំណីអាហារ ត្រូវបំពេញសំណុំលិខិត ដូចខាងក្រោម ៖

**ក-ករណីផ្សព្វផ្សាយតាមទូរទស្សន៍ និងវិទ្យុ**

-ពាក្យសុំផ្សព្វផ្សាយ ១ច្បាប់(មានតែម្ប)

-វិញ្ញាបនបត្រអនាម័យផលិតផលចំណីអាហារ ឬបញ្ជាក់ការដាក់លក់ផលិតផលចំណីអាហារ(ថតចម្លង) ១ច្បាប់

-សេចក្តីព្រាងអត្ថបទផ្សព្វផ្សាយ ១ច្បាប់
-កាសែតវីដេអូ DVD ឬVCD ឬCD ជាSport គំរូ ១ច្បាប់
-ផលិតផលគំរូដែលត្រូវផ្សព្វផ្សាយ ២ឯកតា

**ខ-ករណីផ្សព្វផ្សាយតាមព័ត៌មាន ឬទស្សនាវដ្តី ឬប្រតិទិន ឬសៀវភៅផ្សព្វផ្សាយពាណិជ្ជកម្ម ឬប័ណ្ណប្រកាសរូបភាព ឬខិត្តប័ណ្ណ ឬសម្ភារប្រើប្រាស់ផ្សេងៗ ឬមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ**

-ពាក្យសុំផ្សព្វផ្សាយ ១ច្បាប់(មានគំរូ)
-វិញ្ញាបនបត្រអនាម័យផលិតផលចំណីអាហារ ឬបញ្ជាក់ការដាក់លក់ផលិតផលចំណីអាហារ(ថតចម្លង) ១ច្បាប់
-សេចក្តីព្រាងអត្ថបទផ្សព្វផ្សាយ ១ច្បាប់
-ផលិតផលគំរូដែលត្រូវផ្សព្វផ្សាយ ២ឯកតា

**គ-ករណីធ្វើសិក្ខាសាលា ឬប្រជុំតុមូល ឬក្នុងកម្មវិធីផ្សេងៗ**

-ពាក្យសុំផ្សព្វផ្សាយ ១ច្បាប់(មានគំរូ)
-វិញ្ញាបនបត្រអនាម័យផលិតផលចំណីអាហារ ឬបញ្ជាក់ការដាក់លក់ផលិតផលចំណីអាហារ(ថតចម្លង) ១ច្បាប់
-កម្មវិធី ១ច្បាប់

**ប្រការ៧ .-**

ការផ្សព្វផ្សាយផលិតផលចំណីអាហារតាមរយៈវិទ្យុ ទូរទស្សន៍ គេហទំព័រ ប្រតិទិន បណ្តាញសង្គម សារព័ត៌មាន ទស្សនាវដ្តី ខិត្តប័ណ្ណ(Leaflet) ប័ណ្ណប្រកាសរូបភាព(Poster) ផ្ទាំងប៉ាណូ ប្រអប់ភ្លើងផ្សាយពាណិជ្ជកម្ម សិក្ខាសាលា តាំងពិពណ៌ ស្លាកយីហោ និងតាមរូបភាពផ្សេងៗទៀត អាចប្រព្រឹត្តទៅបានលុះត្រាតែមានការអនុញ្ញាតិពីក្រសួងសុខាភិបាល។

**ប្រការ៨ .-**

លិខិតរបស់ក្រសួងសុខាភិបាល ដែលអនុញ្ញាតឱ្យផ្សព្វផ្សាយពាណិជ្ជកម្មផលិតផលចំណីអាហារមានសុពលភាព ០១ឆ្នាំ។ ចំពោះសិក្ខាសាលា តាំងពិព័រណ៍ និងតាំងបង្ហាញ មានសុពលភាពមិនលើសពី ០១ ខែ។ មុនផុតសុពលភាព ០១ខែ ម្ចាស់គ្រឹះស្ថានផលិត អ្នកនាំចូល អ្នកចែកចាយផលិតផលចំណីអាហារត្រូវមកសុំបន្តសុពលភាពវិញ្ញាបនបត្រផ្សព្វផ្សាយពាណិជ្ជកម្មផលិតផលចំណីអាហារនៅក្រសួងសុខាភិបាល ក្នុងករណីមានការផ្សព្វផ្សាយបន្តទៀត។

**ប្រការ៩ .-**

ក្រសួងសុខាភិបាល និងផ្តល់លិខិតអនុញ្ញាតឱ្យផ្សព្វផ្សាយពាណិជ្ជកម្មផលិតផលចំណីអាហារក្នុងរយៈពេលអតិបរិមា ២០ថ្ងៃ (ថ្ងៃធ្វើការ) បន្ទាប់ពីទទួលបានឯកសារគ្រប់គ្រាន់ និងត្រឹមត្រូវ។

**ប្រការ១០ .-**

ក្នុងករណីដែលរកឃើញ ឬមានការប្រកាសអាសន្នពីអាជ្ញាធរមានសមត្ថកិច្ចថាផលិតផលចំណីអាហារនោះមានការប៉ះពាល់ដល់សុខភាព ឬគ្រោះថ្នាក់ដល់អ្នកបរិភោគ ក្រសួងសុខាភិបាលមានសិទ្ធដកហូតយកលិខិតអនុញ្ញាតិដែលចេញដោយក្រសួងសុខាភិបាល។ ក្នុងករណីនេះម្ចាស់គ្រឹះស្ថាននាំចូល ផលិតករ អ្នកចែកចាយ ផលិតផលចំណីអាហារ ត្រូវប្រមូលត្រឡប់មកវិញនូវផលិតផលទាំងនេះដោយម្ចាស់ការ និងសហការជាមួយក្រសួងសុខាភិបាល ឬអាជ្ញាធរពាក់ព័ន្ធ។

**ប្រការ១១ .-**

ម្ចាស់គ្រឹះស្ថាននាំចូល ផលិតករ អ្នកចែកចាយ ផលិតផលចំណីអាហារ ត្រូវបង់ប្រាក់សេវាដែលកំណត់ដោយប្រកាសរួមរវាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយក្រសួងសុខាភិបាល។

**ប្រការ១២ .-**

ម្ចាស់គ្រឹះស្ថាននាំចូល ផលិតករ អ្នកចែកចាយ ផលិតផលចំណីអាហារ ដែលបានប្រព្រឹត្តិល្មើសផ្ទុយនឹងខ្លឹមសារដូចមានចែងក្នុងប្រកាសនេះ ត្រូវពិន័យអន្តរការតាមប្រកាសរួមរវាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយក្រសួងសុខាភិបាល។

ការប្រព្រឹត្តល្មើសក្នុងប្រកាសនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ដែលមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវា។

**ប្រការ១៣ .-**

បទប្បញ្ញត្តិណាដែលចែងផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៤ .-**

នាយកខុទ្ទកាល័យក្រសួងសុខាភិបាល អគ្គនាយករដ្ឋបាល និងហរិញ្ញវត្ថុ អគ្គនាយកបច្ចេកទេសសុខាភិបាល អគ្គាធិការ ប្រធាននាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង និងប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្ត ត្រូវអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ[illegible]ខែ[illegible]ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃ ១០ ខែ តុលា ឆ្នាំ២០១៩

ម៉ម ប៊ុនហេង

**<u>កន្លែងទទួល</u>**

-ទីស្តីការគណៈរដ្ឋមន្ត្រី(ដើម្បីជ្រាបជាព័ត៌មាន)
-គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ(ដើម្បីសហការ)
-សាលារាជធានី ខេត្ត
-ដូចក្នុងប្រការ១៤(ដើម្បីអនុវត្ត)
-រាជកិច្ច
-ឯកសារ និងកាលប្បវត្តិ